# ព្រះរាជក្រម

នស/រកម/១១២០/០៣៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការហាមឃាត់អាវុធនុយក្លេអ៊ែរ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី៤ ហើយដែល មានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើសន្ធិសញ្ញា ស្តីពីការហាមឃាត់អាវុធនុយក្លេអ៊ែរ

**មាត្រា១ .-**

អនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការហាមឃាត់អាវុធនុយក្លេអ៊ែរ ដែលធ្វើនៅទីក្រុងញូវយ៉ក នៃសហរដ្ឋអាមេរិក នាថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៧ ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខានៅទីក្រុងញូវយ៉កនៃសហរដ្ឋអាមេរិក នាថ្ងៃទី៩ ខែមករា ឆ្នាំ២០១៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា២ .-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តសន្ធិសញ្ញានេះ។

**មាត្រា៣ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ ពុធ ១០កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០២០

នរ.ស/រកម.១១២០.០២៤

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**សម្តេចពិជ័យសេនា ទៀ បាញ់**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
លេខៈ ៥២៧៦ អជ.កបទ.សអ

**សូមជម្រាបមក**
**ឯកឧត្តម ឯកអគ្គរាជទូត តំណាងអចិន្ត្រៃយ៍កម្ពុជា**
**ប្រចាំអ.ស.ប នៅទីក្រុងញូវយ៉ក**

**កម្មវត្ថុៈ** ការផ្តល់ឈ្មោះ និងតួនាទីឧត្តមមន្ត្រីតំណាងកម្ពុជា ចុះហត្ថលេខាលើសន្ធិសញ្ញាស្តីពីការហាមឃាត់អាវុធនុយក្លេអ៊ែរ។

**យោងៈ** យោងចំណារឯកភាពរបស់ សម្តេចតេជោនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

ខ្ញុំសូមជម្រាបជូន ឯកឧត្តម ថា ក្រសួងបានសម្រេចចាត់ ឯកឧត្តម ជាតំណាងកម្ពុជា ដើម្បីចុះហត្ថលេខាលើសន្ធិសញ្ញាស្តីពីការហាមឃាត់អាវុធនុយក្លេអ៊ែរ (Treaty on the Prohibition of Nuclear Weapons - TPNW) ដែលកម្ពុជាបានបោះឆ្នោតគាំទ្រសេចក្តីព្រាងសន្ធិសញ្ញានេះកាលពីឆ្នាំ២០១៧ កន្លងមក។

សូមជូនភ្ជាប់មកនូវលិខិតសិទ្ធិប្រទាន និងឯកសារពាក់ព័ន្ធ។

សូម ឯកឧត្តម អនុវត្តតាមការណែនាំនេះ ឲ្យបានឆាប់តាមការគួរ។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨

**ជ. រដ្ឋមន្ត្រី**
**អនុរដ្ឋលេខាធិការ**

**សុខ សុភេន**

ចម្លងជូនៈ
- អាជ្ញាធរជាតិអាវុធគីមី
- ឯកសារ-កាលប្បវត្តិ

អាសយដ្ឋានៈ លេខ ៣ វិថីសម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

Media from www.moj.gov.kh resource from www.ocm.gov.kh

# សន្ធិសញ្ញា
# ស្ដីពី
# ការហាមឃាត់អាវុធនុយក្លេអ៊ែរ

រដ្ឋភាគីនៃសន្ធិសញ្ញានេះ៖

ដោយបានប្ដេជ្ញាចិត្តចូលរួមសម្រេចគោលបំណងនិងគោលការណ៍នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ។

ដោយព្រួយបារម្ភយ៉ាងខ្លាំងអំពីមហន្តរាយមនុស្សជាតិ ដែលជាលទ្ធផលកើតចេញពីការប្រើប្រាស់អាវុធនុយក្លេអ៊ែរនិងការទទួលស្គាល់តម្រូវការចាំបាច់ក្នុងការលុបបំបាត់ទាំងស្រុងនូវអាវុធប្រភេទនេះដែលនេះជាមធ្យោបាយតែមួយគត់ដើម្បីធានាថា អាវុធនុយក្លេអ៊ែរមិនត្រូវបានយកទៅប្រើប្រាស់ម្ដងទៀតឡើយទោះបីក្នុងកាលៈទេសៈណាក៏ដោយ។

ដោយដឹងអំពីហានិភ័យដែលបង្កឡើងដោយការបន្តមានអាវុធនុយក្លេអ៊ែរ រាប់បញ្ចូលទាំងការបំផ្ទុះអាវុធនុយក្លេអ៊ែរណាមួយដោយចៃដន្យ កំហុសក្នុងការគណនា ឬការរចនា និងសង្កត់ធ្ងន់ថា ហានិភ័យទាំងនេះពាក់ព័ន្ធនឹងសុវត្ថិភាពរបស់មនុស្សជាតិហើយថារដ្ឋទាំងអស់មានទំនួលខុសត្រូវចូលរួមបង្ការការប្រើប្រាស់អាវុធនុយក្លេអ៊ែរ។

ដោយយល់ដឹងថា ផលវិបាកដ៏មហន្តរាយនៃអាវុធនុយក្លេអ៊ែរមិនអាចត្រូវបានដោះស្រាយដោយសមស្របឡើយ ដោយវារាលដាលហួសពីព្រំដែនប្រទេសជាតិ និងបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់ការរស់រានមានជីវិតរបស់មនុស្ស បរិស្ថាន ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម សេដ្ឋកិច្ចសកល សន្តិសុខស្បៀង និងសុខភាពរបស់មនុស្សជំនាន់បច្ចុប្បន្ននិងជំនាន់ក្រោយ ហើយមានផលប៉ះពាល់ដោយវិសមាមាត្រលើស្ត្រីនិងក្មេងស្រីរួមទាំងលទ្ធផលនៃចំហាយវិទ្យុសកម្មដែលមានជាតុអ៊ីយ៉ុង។

ដោយទទួលស្គាល់ក្រមសីលធម៌សម្រាប់ការរំសាយអាវុធនុយក្លេអ៊ែរនិងភាពបន្ទាន់នៃការសម្រេចនិងរក្សាបានពិភពលោកដែលគ្មានអាវុធនុយក្លេអ៊ែរ ដែលនេះជាការងារសប្បុរសធម៌ដ៏ឧត្តុង្គឧត្តមបំផុតលើពិភពលោកសម្រាប់បម្រើដល់ផលប្រយោជន៍សន្តិសុខជាតិនិងសមូហភាព។

ដោយដឹងអំពីការឈឺចាប់និងគ្រោះថ្នាក់ដែលមិនអាចទទួលយកបានចំពោះជនរងគ្រោះដោយសារការប្រើប្រាស់អាវុធនុយក្លេអ៊ែរ (hibakusha) និងការសាកល្បងអាវុធនុយក្លេអ៊ែរ។

ដោយទទួលស្គាល់ថា សកម្មភាពអាវុធនុយក្លេអ៊ែរ មានផលប៉ះពាល់ច្រើនហួសប្រមាណទៅលើមនុស្សគ្រប់ជាតិសាសន៍។

ដោយបញ្ជាក់ម្ដងទៀតអំពីតម្រូវការដែលរដ្ឋទាំងអស់ត្រូវតែអនុវត្តគ្រប់ពេលវេលាតាមច្បាប់អន្តរជាតិរួមទាំងច្បាប់មនុស្សធម៌អន្តរជាតិនិងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

ដោយផ្អែកលើគោលការណ៍និងវិធានការនៃច្បាប់មនុស្សធម៌អន្តរជាតិ ជាពិសេស គឺសិទ្ធិរបស់ភាគីទាំងអស់ក្នុងជម្លោះប្រដាប់អាវុធក្នុងការជ្រើសរើសវិធីសាស្ត្រឬមធ្យោបាយធ្វើសង្គ្រាម ដែលមិនកំណត់ត្រឹមវិធានការប្រើប្រាស់កម្លាំងទ័ពដោយស្របច្បាប់ ហាមឃាត់ការវាយប្រហារដោយមិនកំណត់គោលដៅវិធានការវាយប្រហារគោលដៅដែលបង្កគ្រោះថ្នាក់ដល់ជនស៊ីវិលឬទ្រព្យសម្បត្តិជនស៊ីវិល ការហាមឃាត់ការប្រើប្រាស់អាវុធដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ឬការរងទុក្ខដែលមិនចាំបាច់ និងច្បាប់ដើម្បីការពារបរិស្ថានធម្មជាតិ។/ុ

ដោយពិចារណាថា ការប្រើប្រាស់អាវុធនុយក្លេអ៊ែរណាមួយជាការរំលោភបំពានលើច្បាប់អន្តរជាតិ ដែលត្រូវអនុវត្តក្នុងជម្លោះប្រដាប់អាវុធ ជាពិសេស គឺរំលោភបំពានគោលការណ៍និងវិធានការនៃច្បាប់មនុស្សធម៌អន្តរជាតិ។

ដោយបញ្ជាក់ជាថ្មីម្តងទៀតថា ការប្រើប្រាស់អាវុធនុយក្លេអ៊ែរណាមួយមិនអាចទទួលយកបានចំពោះគោលការណ៍មនុស្សជាតិនិងមនសិការសាធារណៈ។

ដោយរំលឹកឡើងវិញថា ដោយអនុលោមទៅតាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ រដ្ឋទាំងអស់មិនត្រូវគំរាមកំហែងឬប្រើកម្លាំងទ័ពក្នុងទំនាក់ទំនងអន្តរជាតិរបស់ពួកគេដើម្បីប្រឆាំងនឹងបូរណភាពទឹកដីឬឯករាជ្យភាពនយោបាយរបស់រដ្ឋណាមួយ ឬក្នុងលក្ខណៈផ្សេងទៀតដែលមិនសមស្របតាមគោលបំណងរបស់អង្គការសហប្រជាជាតិ ហើយត្រូវលើកកម្ពស់ការបង្កើតនិងថែរក្សាសន្តិភាពនិងសន្តិសុខអន្តរជាតិ ហើយថាការបង្កើតនិងការថែរក្សាសន្តិភាពនិងសន្តិសុខអន្តរជាតិ ត្រូវតែមានការលើកកម្ពស់ដោយការប្រើសព្វាវុធតិចតួចបំផុត ដោយបង្វែរទិសដៅនេះឱ្យទៅជាការអភិវឌ្ឍធនធានមនុស្ស និងសេដ្ឋកិច្ចពិភពលោក។

ដោយរំលឹកផងដែរថា សេចក្តីសម្រេចចិត្តទីមួយ ដែលត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៤៦ និងសេចក្តីសម្រេចចិត្តជាបន្តបន្ទាប់ដែលអំពាវនាវឱ្យមានការលុបបំបាត់អាវុធនុយក្លេអ៊ែរ។

ដោយមានការព្រួយបារម្ភអំពីដំណើរយឺតយ៉ាវនៃការរំសាយអាវុធនុយក្លេអ៊ែរ ការបន្តពឹងផ្អែកលើអាវុធនុយក្លេអ៊ែរក្នុងគំនិត ទ្រឹស្តី និងគោលនយោបាយក្នុងផ្នែកយោធានិងសន្តិសុខ ក៏ដូចជាការខ្ជះខ្ជាយធនធានសេដ្ឋកិច្ចនិងធនធានមនុស្សលើផលិតកម្ម ការថែទាំ និងការធ្វើទំនើបកម្មអាវុធនុយក្លេអ៊ែរ។

ដោយទទួលស្គាល់ ថាការហាមឃាត់អាវុធនុយក្លេអ៊ែរដែលមានកាតព្វកិច្ចស្របច្បាប់ បង្កើតបានជាវិភាគទានដ៏សំខាន់មួយឆ្ពោះទៅរកផលសម្រេចនិងការរក្សានូវពិភពលោកមួយដែលគ្មានអាវុធនុយក្លេអ៊ែររួមទាំងការលុបបំបាត់អាវុធនុយក្លេអ៊ែរ ដោយឥតលក្ខខណ្ឌ មិនអាចកែប្រែបាន និងប្រកបដោយតម្លាភាពនិងការប្តេជ្ញាចិត្តអនុវត្តដល់ទីបញ្ចប់។

ដោយប្តេជ្ញាថា នឹងចាត់វិធានការប្រកបដោយទស្សនៈដើម្បីសម្រេចបាននូវវឌ្ឍនភាពប្រកបដោយប្រសិទ្ធភាពឆ្ពោះទៅរកការរំសាយសព្វាវុធជាទូទៅនិងទាំងស្រុង ក្រោមការត្រួតពិនិត្យជាអន្តរជាតិយ៉ាងតឹងរ៉ឹងនិងមានប្រសិទ្ធភាព។

ដោយបញ្ជាក់ជាថ្មី នូវកាតព្វកិច្ចក្នុងការធ្វើនិងបញ្ចប់ការចរចាដោយស្មោះត្រង់ដើម្បីសម្រេចបាននូវគ្រប់ផ្នែកនៃការរំសាយអាវុធនុយក្លេអ៊ែរ ក្រោមការត្រួតពិនិត្យអន្តរជាតិយ៉ាងតឹងរ៉ឹង និងមានប្រសិទ្ធិភាព។

ដោយបញ្ជាក់នូវគោលជំហរជាថ្មីម្តងទៀតថា ការអនុវត្តសន្ធិសញ្ញាស្តីពីការមិនរីកសាយភាយអាវុធនុយក្លេអ៊ែរយ៉ាងពេញលេញនិងមានប្រសិទ្ធភាពជាមូលដ្ឋានគ្រឹះនៃរបបរំសាយអាវុធនុយក្លេអ៊ែរនិងមិនរីកសាយអាវុធនុយក្លេអ៊ែរ អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់សន្តិភាពនិងសន្តិសុខអន្តរជាតិ។

ដោយទទួលស្គាល់ថា សារៈសំខាន់ដ៏ធំធេងនៃសន្ធិសញ្ញាស្តីពីការហាមឃាត់ស្តីពីការសាកល្បងអាវុធនុយក្លេអ៊ែរនិងការពិនិត្យផ្ទៀងផ្ទាត់នៃសន្ធិសញ្ញានេះ ជាធាតុស្នូលមួយនៃការរំសាយអាវុធនុយក្លេអ៊ែរនិងការមិនរីកសាយភាយអាវុធនុយក្លេអ៊ែរ។

ដោយបញ្ជាក់ជាថ្មីនូវការជឿជាក់ថា ការបង្កើតតំបន់ដែលគ្មានអាវុធនុយក្លេអ៊ែរដែលទទួលស្គាល់ជាអន្តរជាតិ ដោយឈរលើមូលដ្ឋាននៃការរៀបចំដោយសេរី ដោយបណ្តារដ្ឋនៅក្នុងតំបន់ពាក់ព័ន្ធទាំងអស់

អាចបង្កើនសន្តិភាពនិងសន្តិសុខតំបន់និងសកល ពង្រឹងដល់ការមិនរីកសាយភាយអាវុធនុយក្លេអ៊ែរ និងរួមចំណែកឆ្ពោះទៅរកការសម្រេចបាននូវគោលបំណងនៃការរំសាយអាវុធនុយក្លេអ៊ែរ។

ដោយការសង្កត់ធ្ងន់ថា គ្មានបទប្បញ្ញត្តិណាមួយនៃសន្ធិសញ្ញានេះត្រូវបានបកស្រាយថា ប៉ះពាល់ដល់សិទ្ធិដែលមិនអាចទទួលយកបានរបស់រដ្ឋភាគីក្នុងការអភិវឌ្ឍ ការស្រាវជ្រាវ ការផលិត និងការប្រើប្រាស់ថាមពលនុយក្លេអ៊ែរក្នុងគោលបំណងសន្តិភាពដោយគ្មានការរើសអើង។

ដោយទទួលស្គាល់ថា ការចូលរួមស្មើភាពគ្នា ពេញលេញ និងមានប្រសិទ្ធភាពរបស់បុរសនិងស្ត្រីគឺជាកត្តាចាំបាច់ក្នុងការលើកកម្ពស់និងសម្រេចបាននូវសន្តិភាពនិងសន្តិសុខប្រកបដោយចីរភាព ហើយប្តេជ្ញាគាំទ្រនិងពង្រឹងការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់ស្ត្រីក្នុងការរំសាយអាវុធនុយក្លេអ៊ែរ។

ដោយយល់ដឹងអំពីសារៈសំខាន់នៃរាល់ទិដ្ឋភាពអប់រំស្តីពីសន្តិភាពនិងការរំសាយសព្វាវុធ និងសារៈសំខាន់នៃការលើកកម្ពស់ការយល់ដឹងអំពីហានិភ័យនិងផលវិបាកនៃអាវុធនុយក្លេអ៊ែរសម្រាប់មនុស្សជាតិជំនាន់បច្ចុប្បន្ននិងមនុស្សជំនាន់ក្រោយ និងប្តេជ្ញាចិត្តធ្វើការផ្សព្វផ្សាយអំពីគោលការណ៍និងបទដ្ឋាននៃសន្ធិសញ្ញានេះ។

ដោយសង្កត់ធ្ងន់លើតួនាទីនៃមនសិការសាធារណៈនៅក្នុងការលើកកម្ពស់គោលការណ៍មនុស្សធម៌ដូចបានបង្ហាញយ៉ាងច្បាស់តាមរយៈការអំពាវនាវសុំឱ្យមានការលុបបំបាត់ចោលទាំងស្រុងនូវអាវុធនុយក្លេអ៊ែរ និងទទួលស្គាល់កិច្ចខិតខំប្រឹងប្រែងរបស់អង្គការសហប្រជាជាតិ អង្គការកាកបាទក្រហម និងអឌ្ឍចន្ទក្រហមអន្តរជាតិ អង្គការក្នុងតំបន់និងអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល មេដឹកនាំសាសនា សមាជិកសភា បញ្ញវន្តនិងជនរងគ្រោះដោយសារអាវុធនុយក្លេអ៊ែរ (hibakusha)។

បានព្រមព្រៀងដូចខាងក្រោម៖

## មាត្រា១
## ការហាមឃាត់

១. រដ្ឋភាគីនីមួយៗ ទោះក្នុងកាលៈទេសៈណាក៏ដោយ មិនត្រូវ៖

(ក) អភិវឌ្ឍ សាកល្បង ផលិត កែច្នៃ (ធ្វើកម្មន្តសាលកម្ម) ឬទទួលយក កាន់កាប់ ឬស្តុកអាវុធនុយក្លេអ៊ែរ ឬឧបករណ៍គ្រឿងផ្ទុះនុយក្លេអ៊ែរផ្សេងៗទៀត។

(ខ) ផ្ទេរអាវុធនុយក្លេអ៊ែរឬឧបករណ៍គ្រឿងផ្ទុះនុយក្លេអ៊ែរផ្សេងៗទៀតឱ្យទៅអ្នកទទួលណាមួយ ឬការគ្រប់គ្រងលើអាវុធ ឬឧបករណ៍គ្រឿងផ្ទុះទាំងនេះដោយផ្ទាល់ឬដោយប្រយោល។

(គ) ទទួលដោយផ្ទាល់ឬដោយប្រយោលនូវការផ្ទេរឬការគ្រប់គ្រងអាវុធនុយក្លេអ៊ែរឬឧបករណ៍គ្រឿងផ្ទុះនុយក្លេអ៊ែរផ្សេងៗទៀត។

(ឃ) ប្រើប្រាស់ឬគំរាមកំហែងថា នឹងប្រើប្រាស់អាវុធនុយក្លេអ៊ែរ ឬឧបករណ៍គ្រឿងផ្ទុះនុយក្លេអ៊ែរផ្សេងៗទៀត។

(ង) ជួយសម្រួល លើកទឹកចិត្ត ឬបញ្ចុះបញ្ចូលបុគ្គលណាមួយ តាមវិធីផ្សេងៗឱ្យចូលរួមក្នុងសកម្មភាពណាមួយដែលត្រូវបានហាមឃាត់ចំពោះរដ្ឋភាគី នៅក្នុងសន្ធិសញ្ញានេះ។

(ច) ស្វែងរកឬទទួលយកជំនួយពីបុគ្គលណាមួយ តាមវិធីផ្សេងៗដើម្បីចូលរួមសកម្មភាពណាមួយដែលត្រូវបានហាមឃាត់ចំពោះរដ្ឋភាគីនៅក្នុងសន្ធិសញ្ញានេះ។



Media from www.moj.gov.kh resource from www.ocm.gov.kh

(ឆ) អនុញ្ញាតឱ្យមានការដាក់ស្ថានីយឬទីតាំង ការដំឡើង ឬការពង្រាយអាវុធនុយក្លេអ៊ែរណាមួយ ឬឧបករណ៍ឬគ្រឿងផ្ទុះនុយក្លេអ៊ែរផ្សេងទៀតក្នុងទឹកដីរបស់ខ្លួនឬនៅកន្លែងណាមួយផ្សេងទៀតនៅក្រោមដែនយុត្តាធិការ ឬការគ្រប់គ្រងរបស់ខ្លួន។

## មាត្រា២
## សេចក្តីប្រកាស

១. រដ្ឋភាគីនីមួយៗ ត្រូវដាក់ជូនសេចក្តីប្រកាសមួយទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ មិនឱ្យលើសពី ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីសន្ធិសញ្ញានេះចូលជាធរមាននៅក្នុងរដ្ឋភាគីនោះ ហើយរដ្ឋភាគីត្រូវ៖

(ក) ប្រកាសថា តើរដ្ឋភាគីជាម្ចាស់កម្មសិទ្ធិ បានកាន់កាប់ឬបានគ្រប់គ្រងអាវុធនុយក្លេអ៊ែរឬឧបករណ៍គ្រឿងផ្ទុះនុយក្លេអ៊ែរ ព្រមទាំងលុបបំបាត់កម្មវិធីអាវុធនុយក្លេអ៊ែររបស់ខ្លួន ដែលរួមបញ្ចូលទាំងការលុបបំបាត់ ឬការផ្លាស់ប្តូររូបរាងឬទ្រង់ទ្រាយដើមដែលមិនអាចត្រឡប់វិញបាននូវរាល់ទីតាំងឬរោងចក្រឬមណ្ឌល ដែលទាក់ទងនឹងអាវុធនុយក្លេអ៊ែរទាំងអស់មុនពេលសន្ធិសញ្ញានេះចូលជាធរមានសម្រាប់រដ្ឋភាគីនោះ។

(ខ) ប្រកាសថា តើរដ្ឋភាគីជាម្ចាស់កម្មសិទ្ធិ កាន់កាប់ ឬគ្រប់គ្រងអាវុធនុយក្លេអ៊ែរឬឧបករណ៍គ្រឿងផ្ទុះនុយក្លេអ៊ែរផ្សេងៗទៀតដែរឬទេ បើទោះបីជាមានមាត្រា១(ក)ក៏ដោយ។

(គ) ប្រកាសថា តើមានអាវុធនុយក្លេអ៊ែរឬឧបករណ៍គ្រឿងផ្ទុះនុយក្លេអ៊ែរផ្សេងៗទៀតនៅក្នុងទឹកដីរបស់ខ្លួនឬក្នុងកន្លែងណាមួយដែលស្ថិតនៅក្រោមយុត្តាធិការឬការគ្រប់គ្រង ដែលត្រូវបានយកធ្វើជាកម្មសិទ្ធិ ត្រូវបានកាន់កាប់ ឬត្រូវបានគ្រប់គ្រងដោយរដ្ឋភាគីមួយផ្សេងទៀត បើទោះបីជាមានបទប្បញ្ញត្តិនៃមាត្រា១(ឆ)ក៏ដោយ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនរាល់សេចក្តីប្រកាសទាំងអស់ដែលទទួលបានទៅបណ្តារដ្ឋភាគីពាក់ព័ន្ធ។

## មាត្រា៣
## ការការពារសុវត្ថិភាព

១. រដ្ឋភាគីនីមួយៗដែលមិនស្ថិតក្រោមវិសាលភាពនៃមាត្រា៤ កថាខណ្ឌទី១ឬទី២ ក្នុងកម្រិតអប្បបរមា ត្រូវរក្សានូវកាតព្វកិច្ចនៃការការពារចំពោះទីភ្នាក់ងារថាមពលបរមាណូអន្តរជាតិរបស់ខ្លួនឱ្យមានប្រសិទ្ធភាព នៅពេលសន្ធិសញ្ញានេះបានចូលជាធរមាន ដោយមិនមានផលប៉ះពាល់ណាមួយដល់ឯកសារឬលិខិតុបករណ៍ពាក់ព័ន្ធបន្ថែមផ្សេងៗដែលអាចនឹងត្រូវបានអនុម័តនាពេលអនាគត។

២. រដ្ឋភាគីនីមួយៗដែលមិនស្ថិតក្រោមវិសាលភាពនៃមាត្រា៤ កថាខណ្ឌទី១ឬទី២ ហើយមិនទាន់បានធ្វើនៅឡើយ ត្រូវសម្រេចកិច្ចព្រមព្រៀងជាមួយទីភ្នាក់ងារថាមពលបរមាណូអន្តរជាតិនិងដាក់ឱ្យចូលជាធរមាននូវកិច្ចព្រមព្រៀងនៃការការពារសុវត្ថិភាពទូលំទូលាយមួយ (INFCIRC/153 (Corrected))។ ការចរចាលើកិច្ចព្រមព្រៀងបែបនេះ ត្រូវចាប់ផ្តើមក្នុងរយៈពេល១៨០(មួយរយប៉ែតសិប)ថ្ងៃ ចាប់ពីការចូលជាធរមាននៃសន្ធិសញ្ញានេះសម្រាប់រដ្ឋភាគីនោះ។ កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមានមិនឱ្យលើសពីរយៈពេល១៨(ដប់ប្រាំបី)ខែចាប់ពីការចូលជាធរមាននៃសន្ធិសញ្ញានេះសម្រាប់រដ្ឋភាគីនោះ។ បន្ទាប់មក រដ្ឋភាគីនីមួយៗ ត្រូវរក្សាកាតព្វកិច្ចបែបនេះ ដោយមិនមានផលប៉ះពាល់ណាមួយដល់ឯកសារឬលិខិតុបករណ៍ពាក់ព័ន្ធបន្ថែមផ្សេងៗដែលអាចនឹងត្រូវបានអនុម័តនាពេលអនាគតឡើយ។៚



Media from www.moj.gov.kh resource from www.ocm.gov.kh

## មាត្រា៤
## ដំណើរឆ្ពោះទៅរកការលុបបំបាត់អាវុធនុយក្លេអ៊ែរទាំងស្រុង

១. ក្រោយពីថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៧ ចំពោះរដ្ឋភាគីណាដែលមានកម្មសិទ្ធិ កាន់កាប់ ឬគ្រប់គ្រងអាវុធនុយក្លេអ៊ែរឬឧបករណ៍គ្រឿងផ្ទុះនុយក្លេអ៊ែរផ្សេងៗទៀត និងបានលុបបំបាត់កម្មវិធីអាវុធនុយក្លេអ៊ែររបស់ខ្លួន ដែលរួមបញ្ចូលទាំងការលុបបំបាត់ឬការផ្លាស់ប្តូររូបរាងឬទ្រង់ទ្រាយដើមដែលមិនអាចត្រឡប់វិញបាននូវរាល់ទីតាំង ឬរោងចក្រ ឬមណ្ឌលដែលទាក់ទងនឹងនុយក្លេអ៊ែរមុនពេលចូលជាធរមាននៃសន្ធិសញ្ញានេះ ត្រូវសហការជាមួយអាជ្ញាធរអន្តរជាតិមានសមត្ថកិច្ច ដែលបានកំណត់ដោយអនុលោមតាមកថាខណ្ឌទី៦នៃមាត្រានេះ សម្រាប់គោលបំណងនៃការផ្ទៀងផ្ទាត់នូវការលុបបំបាត់ចោលជានិរន្តរ៍នៃកម្មវិធីអាវុធនុយក្លេអ៊ែររបស់រដ្ឋភាគី។ អាជ្ញាធរអន្តរជាតិដែលមានសមត្ថកិច្ច គួររាយការណ៍ទៅបណ្តារដ្ឋភាគី។ រដ្ឋភាគីមួយ ត្រូវចុះកិច្ចព្រមព្រៀងស្តីពីការការពារសុវត្ថិភាព ជាមួយទីភ្នាក់ងារថាមពលបរមាណូអន្តរជាតិដើម្បីផ្តល់ការធានាដែលអាចទុកចិត្តបាន នូវការមិនបង្វែរទិសដៅនៃសម្ភារៈនុយក្លេអ៊ែរដែលបានប្រកាសមិនឱ្យប្រាសចាកចេញពីសកម្មភាពនុយក្លេអ៊ែរដើម្បីសន្តិភាព ហើយមិនមានអវត្តមានសម្ភារៈឬសកម្មភាពនុយក្លេអ៊ែរ ដែលមិនត្រូវបានប្រកាសនៅក្នុងរដ្ឋភាគីទាំងមូលឡើយ។ ការចរចាសម្រាប់កិច្ចព្រមព្រៀងបែបនេះត្រូវចាប់ផ្តើមក្នុងរយៈពេល១៨០(មួយរយប៉ែតសិប)ថ្ងៃចាប់ពីថ្ងៃចូលជាធរមាននៃសន្ធិសញ្ញានេះសម្រាប់រដ្ឋភាគីនោះ។ កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមានមិនឱ្យលើសពីរយៈពេល១៨(ដប់ប្រាំបី)ខែ បន្ទាប់ពីសន្ធិសញ្ញានេះចូលជាធរមានសម្រាប់រដ្ឋភាគីនោះ។ បន្ទាប់មក រដ្ឋភាគីនោះយ៉ាងហោចណាស់ត្រូវរក្សាកាតព្វកិច្ចការពារទាំងនេះឱ្យបាន ដោយមិនមានផលប៉ះពាល់ណាមួយដល់ឯកសារឬលិខិតុបករណ៍ពាក់ព័ន្ធបន្ថែមផ្សេងៗដែលអាចនឹងត្រូវបានអនុម័តនាពេលអនាគត។

២. ទោះជាមានបទប្បញ្ញត្តិនៃមាត្រា១(ក)ក៏ដោយ រដ្ឋភាគីនីមួយៗដែលមានកម្មសិទ្ធិ កាន់កាប់ ឬគ្រប់គ្រងអាវុធនុយក្លេអ៊ែរឬឧបករណ៍គ្រឿងផ្ទុះនុយក្លេអ៊ែរផ្សេងៗទៀត ត្រូវបញ្ឈប់ប្រតិបត្តិការភ្លាមៗ ហើយត្រូវបំផ្លាញឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ប៉ុន្តែមិនលើសពីថ្ងៃផុតកំណត់ដែលបានកំណត់ដោយកិច្ចប្រជុំដំបូងនៃបណ្តារដ្ឋភាគីឡើយ ដោយអនុលោមតាមផែនការមួយដែលចងភ្ជាប់កាតព្វកិច្ចស្របច្បាប់និងមានពេលវេលាកំណត់ ដែលអាចផ្ទៀងផ្ទាត់បាននិងមិនអាចត្រឡប់វិញបានក្នុងការលុបបំបាត់កម្មវិធីអាវុធនុយក្លេអ៊ែររបស់រដ្ឋភាគី ដែលរួមបញ្ចូលទាំងការលុបបំបាត់ឬការផ្លាស់ប្តូររូបរាងឬទ្រង់ទ្រាយដែលមិនអាចត្រឡប់វិញបាននូវរាល់ទីតាំងឬរោងចក្រឬមណ្ឌលទាំងអស់ដែលទាក់ទងនឹងអាវុធនុយក្លេអ៊ែរ។ រដ្ឋភាគី ត្រូវបញ្ជូនផែនការនេះទៅបណ្តារដ្ឋភាគីឬអាជ្ញាធរមានសមត្ថកិច្ចអន្តរជាតិ ដែលកំណត់ដោយបណ្តារដ្ឋភាគីក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ បន្ទាប់ពីការចូលជាធរមាននៃសន្ធិសញ្ញានេះសម្រាប់រដ្ឋភាគីនោះ។ បន្ទាប់មកផែនការនេះនឹងត្រូវបានចរចាជាមួយទីភ្នាក់ងារមានសមត្ថកិច្ចអន្តរជាតិ ហើយទីភ្នាក់ងារមានសមត្ថកិច្ចអន្តរជាតិត្រូវបញ្ជូនផែនការនេះទៅកិច្ចប្រជុំបន្ទាប់នៃបណ្តារដ្ឋភាគីឬសន្និសីទពិនិត្យឡើងវិញសម្រាប់ការយល់ព្រមស្របតាមនីតិវិធី។

៣. រដ្ឋភាគីដែលស្ថិតក្រោមវិសាលភាពនៃកថាខណ្ឌទី២ខាងលើ ត្រូវចុះកិច្ចព្រមព្រៀងស្តីពីការការពារសុវត្ថិភាពមួយជាមួយទីភ្នាក់ងារថាមពលបរមាណូអន្តរជាតិ ដើម្បីផ្តល់ការធានាដែលអាចទុកចិត្តបាននៃការមិនបង្វែរទិសដៅនៃសម្ភារៈនុយក្លេអ៊ែរដែលបានប្រកាសមិនឱ្យប្រាសចាកចេញពីសកម្មភាពនុយក្លេអ៊ែរដើម្បីសន្តិភាព និងមិនឱ្យមានអវត្តមាននៃសម្ភារៈឬសកម្មភាពនុយក្លេអ៊ែរ ដែលមិនត្រូវបានប្រកាសនៅក្នុង ...

រដ្ឋភាគីទាំងមូលឡើយ។ ការចរចាលើកិច្ចព្រមព្រៀងបែបនេះត្រូវចាប់ផ្ដើមមិនលើសពីកាលបរិច្ឆេទនៃការអនុវត្តផែនការដូចមានចែងនៅក្នុងកថាខណ្ឌទី២ត្រូវបានបញ្ចប់ឡើយ។ កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមានមិនឱ្យលើសពី១៨(ដប់ប្រាំបី)ខែ បន្ទាប់ពីការចាប់ផ្ដើមការចរចា។ បន្ទាប់មក រដ្ឋភាគីនោះយ៉ាងហោចណាស់ត្រូវរក្សាកាតព្វកិច្ចការពារទាំងនេះឱ្យបាន ដោយមិនមានផលប៉ះពាល់ណាមួយដល់ឯកសារ ឬលិខិតុបករណ៍ពាក់ព័ន្ធបន្ថែមផ្សេងៗដែលអាចនឹងត្រូវបានអនុម័តនាពេលអនាគត។ បន្ទាប់ពីកិច្ចព្រមព្រៀងដូចមានចែងនៅក្នុងកថាខណ្ឌនេះចូលជាធរមាន រដ្ឋភាគីត្រូវបញ្ជូនសេចក្ដីប្រកាសចុងក្រោយបង្អស់ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិដោយបញ្ជាក់ថា ខ្លួនបានបំពេញកាតព្វកិច្ចនានារបស់ខ្លួនដូចមានចែងក្នុងមាត្រានេះ។

៤. ទោះបីជាមានបទប្បញ្ញត្តិនៃមាត្រា១ កថាខណ្ឌ(ខ)និង(ឆ)ក៏ដោយ រដ្ឋភាគីនីមួយៗដែលមានអាវុធនុយក្លេអ៊ែរឬឧបករណ៍គ្រឿងផ្ទុះនុយក្លេអ៊ែរផ្សេងៗទៀតនៅក្នុងទឹកដីរបស់ខ្លួនឬកន្លែងណាមួយដែលស្ថិតនៅក្រោមដែនយុត្តាធិការឬការគ្រប់គ្រងរបស់ខ្លួន ប៉ុន្តែត្រូវបានជាកម្មសិទ្ធិ កាន់កាប់ ឬគ្រប់គ្រងដោយរដ្ឋមួយផ្សេងទៀត រដ្ឋភាគីនោះត្រូវធានាថា អាវុធទាំងនេះត្រូវបានរុះរើឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ប៉ុន្តែមិនឱ្យលើសពីថ្ងៃផុតកំណត់ដែលបានកំណត់ដោយកិច្ចប្រជុំលើកដំបូងនៃបណ្ដារដ្ឋភាគីទេ។ បន្ទាប់ពីអាវុធទាំងនេះឬឧបករណ៍គ្រឿងផ្ទុះផ្សេងៗទៀតត្រូវបានដកចេញ រដ្ឋភាគីនោះត្រូវបញ្ជូនទៅឱ្យអគ្គលេខាធិការអង្គការសហប្រជាជាតិនូវសេចក្ដីប្រកាសមួយដែលបញ្ជាក់ថា ខ្លួនបានបំពេញកាតព្វកិច្ចរបស់ខ្លួនដូចមានចែងនៅក្នុងមាត្រានេះ។

៥. រដ្ឋភាគីនីមួយៗ ដែលស្ថិតនៅក្រោមវិសាលភាពនៃមាត្រានេះ ត្រូវដាក់របាយការណ៍មួយជូនទៅគ្រប់កិច្ចប្រជុំបណ្ដារដ្ឋភាគីនិងសន្និសីទពិនិត្យឡើងវិញនីមួយៗ ដោយបញ្ជាក់អំពីវឌ្ឍនភាពនៃការអនុវត្តកាតព្វកិច្ចរបស់ខ្លួនដូចមានចែងនៅក្នុងមាត្រានេះ រហូតដល់ពេលកាតព្វកិច្ចទាំងនេះត្រូវបានបំពេញ។

៦. រដ្ឋភាគី ត្រូវចាត់តាំងអាជ្ញាធរអន្តរជាតិដែលមានសមត្ថកិច្ចមួយឬច្រើនដើម្បីចរចានិងផ្ទៀងផ្ទាត់ការលុបបំបាត់ជានិរន្តរ៍នៃកម្មវិធីអាវុធនុយក្លេអ៊ែរ រួមទាំងការលុបបំបាត់ឬការផ្លាស់ប្ដូររូបរាងឬទ្រង់ទ្រាយជានិរន្តរ៍នូវរាល់ទីតាំង ឬរោងចក្រ ឬមណ្ឌលដែលទាក់ទងនឹងអាវុធនុយក្លេអ៊ែរទាំងអស់ ស្របតាមកថាខណ្ឌទី១ ទី២ និងទី៣នៃមាត្រានេះ។ ប្រសិនបើ ការចាត់តាំងមិនត្រូវបានធ្វើឡើងមុនពេលចូលជាធរមាននៃសន្ធិសញ្ញានេះសម្រាប់រដ្ឋភាគីណាមួយ ដែលស្ថិតក្រោមវិសាលភាពនៃកថាខណ្ឌទី១ឬទី២នៃមាត្រានេះ អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវកោះប្រជុំវិសាមញ្ញនៃបណ្ដារដ្ឋភាគីដើម្បីធ្វើការសម្រេចចិត្តណាមួយដែលចាំបាច់។

## មាត្រា៥
## ការអនុវត្តថ្នាក់ជាតិ

១. រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់នានាដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួនក្រោមសន្ធិសញ្ញានេះ។

២. រដ្ឋភាគីនីមួយៗ ត្រូវចាត់គ្រប់វិធានការផ្លូវច្បាប់ វិធានការរដ្ឋបាល និងវិធានការសមស្របផ្សេងៗទៀត រួមទាំងការដាក់ទណ្ឌកម្មព្រហ្មទណ្ឌ ដើម្បីបង្ការនិងបង្ក្រាបរាល់សកម្មភាពណាមួយដែលត្រូវបានហាមឃាត់ចំពោះរដ្ឋភាគីណាមួយនៅក្រោមសន្ធិសញ្ញានេះ ដែលត្រូវបានប្រព្រឹត្តដោយបុគ្គលណាមួយឬនៅក្នុងដែនដីក្រោមយុត្តាធិការ ឬការគ្រប់គ្រងរបស់ខ្លួន។៚



Media from www.moj.gov.kh resource from www.ocm.gov.kh

## មាត្រា៦
## ជំនួយជនរងគ្រោះនិងការស្តារបរិស្ថាន

១. រដ្ឋភាគីនីមួយៗ ត្រូវផ្តល់ជំនួយឱ្យបានគ្រប់គ្រាន់ដោយគិតពីវ័យឬអាយុ និងយេនឌ័រ ដោយគ្មានការរើសអើង ក្នុងនោះរួមមានការថែទាំផ្នែកវេជ្ជសាស្ត្រ ការគាំទ្រផ្នែកការស្តារនីតិសម្បទានិងចិត្តសាស្ត្រ ព្រមទាំងផ្តល់ការចូលរួមឬបរិយាបន្នសង្គមនិងសេដ្ឋកិច្ចផងដែរ ចំពោះបុគ្គលទាំងឡាយដែលស្ថិតក្រោមដែនយុត្តាធិការបស់ខ្លួន ហើយដែលបានទទួលរងផលប៉ះពាល់ដោយការប្រើប្រាស់ឬការសាកល្បងអាវុធនុយក្លេអ៊ែរ ដោយអនុលោមតាមការអនុវត្តច្បាប់មនុស្សធម៌អន្តរជាតិនិងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។

២. រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់និងសមស្របនានាដើម្បីធ្វើការស្តារបរិស្ថានក្នុងតំបន់ដែលទទួលរងការពុលខ្លាំង ចំពោះតំបន់ទាំងឡាយណាដែលស្ថិតក្រោមដែនយុត្តាធិការឬការគ្រប់គ្រងរបស់ខ្លួនដែលបានទទួលរងនូវការបំពុលដោយសារសកម្មភាពនានាពាក់ព័ន្ធនឹងការសាកល្បងឬការប្រើប្រាស់អាវុធនុយក្លេអ៊ែរឬឧបករណ៍គ្រឿងផ្ទុះនុយក្លេអ៊ែរផ្សេងៗទៀត។

៣. កាតព្វកិច្ចនានាក្នុងកថាខណ្ឌទី១និងទី២ខាងលើ មិនរាប់បញ្ចូលការទទួលខុសត្រូវនិងកាតព្វកិច្ចរបស់ប្រទេសណាមួយក្រោមច្បាប់អន្តរជាតិឬកិច្ចព្រមព្រៀងទ្វេភាគីឡើយ។

## មាត្រា៧
## កិច្ចសហប្រតិបត្តិការនិងជំនួយអន្តរជាតិ

១. រដ្ឋភាគីនីមួយៗ ត្រូវសហប្រតិបត្តិការជាមួយរដ្ឋភាគីផ្សេងទៀតដើម្បីសម្របសម្រួលការអនុវត្តសន្ធិសញ្ញានេះ។

២. រដ្ឋភាគីនីមួយៗ មានសិទ្ធិស្វែងរកនិងទទួលយកជំនួយពីរដ្ឋភាគីផ្សេងទៀតដែលអាចធ្វើទៅបានដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួនក្រោមសន្ធិសញ្ញានេះ។

៣. ស្ថិតក្នុងតួនាទីនៃការអនុវត្តរបស់ខ្លួន រដ្ឋភាគីនីមួយៗត្រូវផ្តល់ជំនួយបច្ចេកទេស ជំនួយសម្ភារៈ និងជំនួយហិរញ្ញវត្ថុដល់រដ្ឋភាគីទាំងឡាយណាដែលរងការប៉ះពាល់ដោយការប្រើប្រាស់ឬការសាកល្បងអាវុធនុយក្លេអ៊ែរដើម្បីបន្តអនុវត្តសន្ធិសញ្ញានេះបន្ថែមទៀត។

៤. ស្ថិតក្នុងតួនាទីនៃការអនុវត្តរបស់ខ្លួន រដ្ឋភាគីនីមួយៗ ត្រូវផ្តល់ជំនួយដល់ជនរងគ្រោះដែលទទួលរងគ្រោះដោយសារការប្រើប្រាស់ឬការសាកល្បងអាវុធនុយក្លេអ៊ែរឬឧបករណ៍គ្រឿងផ្ទុះនុយក្លេអ៊ែរផ្សេងៗទៀត។

៥. ជំនួយក្រោមមាត្រានេះ អាចផ្តល់ជូនក្នុងចំណោមបណ្តាជំនួយនានា តាមរយៈទម្រង់របស់អង្គការសហប្រជាជាតិ អង្គការឬស្ថាប័នអន្តរជាតិ អង្គការឬស្ថាប័នតំបន់និងអង្គការឬស្ថាប័នជាតិ អង្គការឬស្ថាប័នអង្គការមិនមែនរដ្ឋាភិបាល គណៈកម្មការកាកបាទក្រហមអន្តរជាតិ និងសហព័ន្ធអន្តរជាតិនៃសមាគមកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ឬផ្អែកលើមូលដ្ឋានទ្វេភាគី។

៦. ដោយមិនប៉ះពាល់ដល់ភារកិច្ចឬកាតព្វកិច្ចផ្សេងទៀតដែលខ្លួនមានក្រោមច្បាប់អន្តរជាតិ រដ្ឋភាគីដែលបានប្រើប្រាស់ឬបានសាកល្បងអាវុធនុយក្លេអ៊ែរឬឧបករណ៍គ្រឿងផ្ទុះនុយក្លេអ៊ែរផ្សេងៗ ត្រូវមានការទទួលខុសត្រូវក្នុងការផ្តល់ជំនួយគ្រប់គ្រាន់ដល់រដ្ឋភាគីទាំងឡាយដែលរងការប៉ះពាល់ក្នុងគោលបំណងជាជំនួយដល់ជនរងគ្រោះនិងការស្តារបរិស្ថាន។



Media from www.moj.gov.kh resource from www.ocm.gov.kh

## មាត្រា៨
## ការប្រជុំរបស់បណ្តារដ្ឋភាគី

១. រដ្ឋភាគីទាំងអស់ត្រូវប្រជុំជាទៀងទាត់ដើម្បីពិចារណា ហើយនៅពេលចាំបាច់ត្រូវសម្រេចចិត្តលើបញ្ហានានាដែលទាក់ទងទៅនឹងការប្រើប្រាស់ឬការអនុវត្តសន្ធិសញ្ញានេះ និងវិធានការរំសាយអាវុធនុយក្លេអ៊ែរបន្ថែមទៀត ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធនៃសន្ធិសញ្ញាស្តីពីការហាមឃាត់អាវុធនុយក្លេអ៊ែរ រួមមាន៖

(ក) ការអនុវត្តនិងលក្ខន្តិកៈនៃសន្ធិសញ្ញានេះ។

(ខ) វិធានការនៃការផ្ទៀងផ្ទាត់ពេលវេលាកំណត់ និងការរំលាយជានិរន្តរ៍នៃកម្មវិធីលុបបំបាត់អាវុធនុយក្លេអ៊ែរ ទាំងពិធីសារបន្ថែមទៅលើសន្ធិសញ្ញានេះផងដែរ។

(គ) បញ្ហាផ្សេងៗទៀតត្រូវអនុលោមនិងស្របទៅតាមបទប្បញ្ញត្តិនៃសន្ធិសញ្ញានេះ។

២. កិច្ចប្រជុំលើកដំបូងរបស់រដ្ឋភាគី ត្រូវរៀបចំឡើងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិក្នុងរយៈពេល ១(មួយ)ឆ្នាំ បន្ទាប់ពីការចូលជាធរមាននៃសន្ធិសញ្ញានេះ។ កិច្ចប្រជុំជាបន្តរបស់រដ្ឋភាគី ត្រូវរៀបចំធ្វើឡើងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិក្នុងរយៈពេល២(ពីរ)ឆ្នាំម្តង លើកលែងតែមានការឯកភាពផ្សេងទៀតក្រៅពីនេះដោយរដ្ឋជាភាគី។ កិច្ចប្រជុំនៃរដ្ឋភាគីនេះ ត្រូវអនុម័តនីតិវិធីនៅសម័យប្រជុំដំបូងរបស់ខ្លួន។ ការព្យួរទុកការអនុម័តរបស់កិច្ចប្រជុំ ត្រូវអនុវត្តតាមនីតិវិធីរបស់សន្និសីទអង្គការសហប្រជាជាតិដើម្បីពិភាក្សាអំពីឯកសារចងភ្ជាប់កាតព្វកិច្ចផ្លូវច្បាប់ ក្នុងការហាមឃាត់អាវុធនុយក្លេអ៊ែរ ដែលឈានទៅរកការលុបបំបាត់ទាំងស្រុងនូវអាវុធទាំងនោះ។

៣. កិច្ចប្រជុំវិសាមញ្ញរបស់រដ្ឋភាគី ត្រូវរៀបចំឡើងតាមការចាំបាច់ដោយអគ្គលេខាធិការអង្គការ សហប្រជាជាតិ ទៅតាមការស្នើសុំជាលាយលក្ខណ៍អក្សររបស់រដ្ឋភាគីណាមួយ ដែលការស្នើសុំនេះត្រូវទទួលបានការគាំទ្រយ៉ាងតិចមួយភាគបីនៃរដ្ឋភាគី។

៤. ក្រោយរយៈពេល៥(ប្រាំ)ឆ្នាំ បន្ទាប់ពីការចូលជាធរមាននៃសន្ធិសញ្ញានេះ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវរៀបចំសន្និសីទដើម្បីពិនិត្យមើលកិច្ចដំណើរការនៃសន្ធិសញ្ញានេះនិងវឌ្ឍនភាពនៅក្នុងការសម្រេចបាននូវគោលបំណងនៃសន្ធិសញ្ញានេះ។ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវរៀបចំសន្និសីទពិនិត្យឡើងវិញបន្ថែមទៀតក្នុងចន្លោះពេល៦(ប្រាំមួយ)ឆ្នាំម្តង ដោយមានវត្ថុបំណងដូចគ្នា លើកលែងតែមានការព្រមព្រៀងដទៃផ្សេងទៀតដោយរដ្ឋភាគី។

៥. រដ្ឋដែលមិនមែនជាភាគីក្នុងសន្ធិសញ្ញានេះ ក៏ដូចជាអង្គភាពពាក់ព័ន្ធតាមទម្រង់អង្គការសហប្រជាជាតិ អង្គការនិងស្ថាប័នអន្តរជាតិពាក់ព័ន្ធផ្សេងៗ អង្គការតំបន់ គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ សហព័ន្ធអន្តរជាតិនៃសមាគមកាកបាទក្រហមនិងអឌ្ឍចន្ទក្រហម និងអង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធ ត្រូវបានអញ្ជើញឱ្យចូលរួមកិច្ចប្រជុំរបស់រដ្ឋភាគីនិងសន្និសីទពិនិត្យឡើងវិញក្នុងនាមជាអ្នកសង្កេតការណ៍។

## មាត្រា៩
## ការចំណាយ

១. ថ្លៃចំណាយលើកិច្ចប្រជុំរបស់រដ្ឋភាគី សន្និសីទពិនិត្យឡើងវិញ និងកិច្ចប្រជុំវិសាមញ្ញរបស់រដ្ឋភាគី ត្រូវរ៉ាប់រងដោយរដ្ឋភាគីនិងរដ្ឋមិនមែនភាគីនៃសន្ធិសញ្ញានេះ ដែលបានចូលរួមក្នុងកិច្ចប្រជុំក្នុងនាមជាអ្នកសង្កេតការណ៍ អនុលោមតាមបទដ្ឋាននៃការវាយតម្លៃរបស់អង្គការសហប្រជាជាតិដែលបានកែសម្រួលយ៉ាងសមស្រប។



Media from www.moj.gov.kh resource from www.ocm.gov.kh

២. ថ្លៃចំណាយដែលកើតមានតាមរយៈអគ្គលេខាធិការអង្គការសហប្រជាជាតិនៅក្នុងការផ្សព្វផ្សាយសេចក្តីប្រកាសនានាតាមមាត្រា២ របាយការណ៍នានាតាមមាត្រា៤ និងវិសោធនកម្មដែលបានស្នើឡើងតាមមាត្រា១០ នៃសន្ធិសញ្ញានេះ ត្រូវរ៉ាប់រងដោយរដ្ឋភាគី អនុលោមតាមបទដ្ឋាននៃការវាយតម្លៃរបស់អង្គការសហប្រជាជាតិដែលបានកែសម្រួលយ៉ាងសមស្រប។

៣. ថ្លៃចំណាយទាក់ទងនឹងការអនុវត្តវិធានការផ្ទៀងផ្ទាត់ដែលមានចែងក្នុងមាត្រា៤និងថ្លៃចំណាយទាក់ទងនឹងការបំផ្លាញអាវុធនុយក្លេអ៊ែរឬឧបករណ៍គ្រឿងផ្ទុះនុយក្លេអ៊ែរផ្សេងៗទៀត និងការលុបបំបាត់កម្មវិធីអាវុធនុយក្លេអ៊ែរ រួមបញ្ចូលទាំងការលុបបំបាត់ឬការផ្លាស់ប្តូររាល់ទីតាំង ឬរោងចក្រ ឬមណ្ឌលដែលទាក់ទងនឹងអាវុធនុយក្លេអ៊ែរទាំងអស់ត្រូវទទួលរ៉ាប់រងដោយរដ្ឋភាគី។

## មាត្រា១០
## វិសោធនកម្ម

១. បន្ទាប់ពីសន្ធិសញ្ញានេះចូលជាធរមាន រដ្ឋភាគីណាមួយអាចស្នើសុំធ្វើវិសោធនកម្មលើសន្ធិសញ្ញានេះនៅពេលណាមួយ។ អត្ថបទនៃវិសោធនកម្មដែលបានស្នើ ត្រូវផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិដែលនឹងចែកចាយតាមទម្រង់រដ្ឋបាលទៅរដ្ឋភាគីទាំងអស់ ហើយស្នើសុំយោបល់ពីរដ្ឋភាគីទាំងនោះថាតើត្រូវពិចារណាលើសំណើនេះឬយ៉ាងណា។ ប្រសិនបើរដ្ឋភាគីភាគច្រើនជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិក្នុងរយៈពេលមិនលើសពី៩០(កៅសិប)ថ្ងៃ ដោយរដ្ឋភាគីទាំងនោះគាំទ្រការពិចារណាលើសំណើវិសោធនកម្ម នោះសំណើវិសោធនកម្មនេះនឹងត្រូវលើកយកមកពិចារណានៅក្នុងកិច្ចប្រជុំរដ្ឋភាគីឬសន្និសីទពិនិត្យឡើងវិញណាមួយដែលប្រជុំមុន។

២. កិច្ចប្រជុំរបស់រដ្ឋភាគី ឬសន្និសីទពិនិត្យឡើងវិញ អាចយល់ស្របលើការធ្វើវិសោធនកម្មដែលត្រូវបានអនុម័តដោយការបោះឆ្នោតជាវិជ្ជមានចំនួនពីរភាគបីនៃសំឡេងភាគច្រើនរបស់រដ្ឋភាគី។ អ្នកតម្កល់ឯកសារត្រូវចែកផ្សាយជូនរដ្ឋភាគីទាំងអស់នូវរាល់ការធ្វើវិសោធនកម្មដែលបានអនុម័តរួច។

៣. ការធ្វើវិសោធនកម្ម ត្រូវចូលជាធរមានសម្រាប់រដ្ឋភាគីនីមួយៗ ដែលបានតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័នឬការទទួលយកវិសោធនកម្ម ក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ ក្រោយពីបានតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័នឬការទទួលស្គាល់នោះ ដោយសំឡេងភាគច្រើនរបស់រដ្ឋជាភាគីនៅពេលធ្វើការអនុម័ត។ បន្ទាប់ពីនេះ ការធ្វើវិសោធនកម្ម ត្រូវចូលជាធរមានសម្រាប់រដ្ឋជាភាគីផ្សេងទៀតក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ បន្ទាប់ពីការតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័នឬការទទួលយកការធ្វើវិសោធនកម្ម។

## មាត្រា១១
## ការដោះស្រាយវិវាទ

១. នៅពេលមានវិវាទកើតឡើងរវាងរដ្ឋភាគីចំនួនពីរឬច្រើន ពាក់ព័ន្ធទៅនឹងការបកស្រាយឬការអនុវត្តសន្ធិសញ្ញានេះ រដ្ឋភាគីដែលជាប់ទាក់ទង ត្រូវពិភាក្សាលើទិដ្ឋភាពនៃការដោះស្រាយវិវាទដោយការចរចាឬមធ្យោបាយសន្តិវិធីផ្សេងទៀតដែលជាជម្រើសរបស់ភាគីវិវាទដោយអនុលោមតាមមាត្រា៣៣នៃធម្មនុញ្ញអង្គការសហប្រជាជាតិ។

២. កិច្ចប្រជុំរបស់រដ្ឋភាគី អាចរួមចំណែកទៅក្នុងការដោះស្រាយវិវាទនោះបាន ដូចជាតាមរយៈស្នើជាភាគីទីបីក្នុងការសម្រុះសម្រួលវិវាទ(Good Office) ស្នើដល់រដ្ឋភាគីពាក់ព័ន្ធដើម្បីចាប់ផ្តើមដំណើរការនីតិវិធី ៥៥

ដោះស្រាយវិវាទទៅតាមជម្រើសរបស់ពួកគេ និងការផ្តល់អនុសាសន៍អំពីការកំណត់ពេលវេលាសម្រាប់នីតិវិធីដែលបានព្រមព្រៀង ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធនៃសន្ធិសញ្ញានេះនិងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ។

**មាត្រា១២**

**សកលភាព**

រដ្ឋជាភាគីនីមួយៗ ត្រូវជំរុញលើកទឹកចិត្តឱ្យរដ្ឋមិនមែនជាភាគីក្នុងសន្ធិសញ្ញានេះ ធ្វើការចុះហត្ថលេខា ផ្តល់សច្ចាប័ន ទទួលយក យល់ព្រម និងចូលជាសមាជិកនៃសន្ធិសញ្ញានេះ ដើម្បីសម្រេចបាននូវគោលដៅនៃការប្រកាន់ខ្ជាប់ជាសកលនៃសន្ធិសញ្ញានេះ។

**មាត្រា១៣**

**ការចុះហត្ថលេខា**

សន្ធិសញ្ញានេះ ត្រូវបានបើកជាចំហសម្រាប់ការចុះហត្ថលេខាដល់រដ្ឋទាំងអស់នៅទីស្នាក់ការអង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉ក ចាប់ពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៧។

**មាត្រា១៤**

**ការផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការចូលជាសមាជិក**

សន្ធិសញ្ញានេះ ស្ថិតក្រោមការផ្តល់សច្ចាប័ន ការទទួលយក ឬការយល់ព្រមពីរដ្ឋហត្ថលេខី។ សន្ធិសញ្ញានេះ ត្រូវបើកចំហសម្រាប់ការចូលជាសមាជិក។

**មាត្រា១៥**

**ការចូលជាធរមាន**

១. សន្ធិសញ្ញានេះ ត្រូវចូលជាធរមានក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ បន្ទាប់ពីលិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការចូលជាសមាជិកលើកទី៥០ ត្រូវបានដាក់តម្កល់ទុក។

២. សម្រាប់រដ្ឋដែលដាក់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការចូលជាសមាជិកបន្ទាប់ពីកាលបរិច្ឆេទនៃការតម្កល់លិខិតុបករណ៍លើកទី៥០នៃការផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការចូលជាសមាជិក សន្ធិសញ្ញានេះត្រូវចូលជាធរមានក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ បន្ទាប់ពីថ្ងៃដែលរដ្ឋនោះបានដាក់តម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការចូលជាសមាជិករបស់ខ្លួន។

**មាត្រា១៦**

**ខរក្សាសិទ្ធិ**

មិនមានខរក្សាសិទ្ធិណាមួយ ត្រូវបានធ្វើឡើងចំពោះមាត្រាទាំងឡាយនៃសន្ធិសញ្ញានេះឡើយ។

**មាត្រា១៧**

**ថេរវេលា និងការដកខ្លួនចេញ**

១. សន្ធិសញ្ញានេះ មិនមានថេរវេលាកំណត់ទេ។

២. នៅក្នុងដែនអធិបតេយ្យភាពរបស់ខ្លួន រដ្ឋភាគីនីមួយៗ ត្រូវមានសិទ្ធិដកខ្លួនចេញពីសន្ធិសញ្ញានេះ ប្រសិនបើ



Media from www.moj.gov.kh resource from www.ocm.gov.kh

ខ្លួនសម្រេចថាមានហេតុការណ៍ខុសប្រក្រតីណាមួយពាក់ព័ន្ធនឹងខ្លឹមសារនៃសន្ធិសញ្ញានេះបានបំផ្លាញដល់ឧត្តមប្រយោជន៍នៃប្រទេសរបស់ខ្លួន។ រដ្ឋភាគីនោះ ត្រូវជូនដំណឹងអំពីការដកខ្លួនចេញនោះទៅដល់អ្នកតម្កល់ឯកសារ។ ការជូនដំណឹងនោះ ត្រូវភ្ជាប់នូវរបាយការណ៍ស្តីពីហេតុការណ៍ខុសប្រក្រតីដែលរដ្ឋភាគីចាត់ទុកថាបានបំផ្លាញដល់ឧត្តមប្រយោជន៍របស់ខ្លួន។

៣. ការដកខ្លួនចេញជាពីសមាជិកភាព នឹងចូលជាធរមានក្នុងរយៈពេល១២(ដប់ពីរ)ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការទទួលបានសេចក្តីជូនដំណឹងនៃការដកខ្លួនចេញពីសមាជិកភាពពីអ្នកតម្កល់ឯកសារ។ ប៉ុន្តែនៅពេលផុតកំណត់រយៈពេល១២(ដប់ពីរ)ខែ ប្រសិនបើរដ្ឋភាគីដែលដកខ្លួនចេញពីសមាជិកភាពនោះគឺជាភាគីមួយក្នុងជម្លោះប្រដាប់អាវុធមួយ រដ្ឋភាគីនោះនៅតែបន្តបំពេញកាតព្វកិច្ចចំពោះសន្ធិសញ្ញានេះនិងកាតព្វកិច្ចពិធីសារបន្ថែមណាមួយរហូតដល់ខ្លួនលែងក្លាយជាភាគីក្នុងជម្លោះប្រដាប់អាវុធនោះតទៅទៀត។

## មាត្រា១៨
## ទំនាក់ទំនងជាមួយកិច្ចព្រមព្រៀងផ្សេងទៀត

ការអនុវត្តសន្ធិសញ្ញានេះ មិនមានផលប៉ះពាល់ដល់កាតព្វកិច្ចទាំងឡាយដែលពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងអន្តរជាតិជាធរមាននៃរដ្ឋភាគីជាភាគីនោះឡើយ ប្រសិនបើកាតព្វកិច្ចទាំងនោះស្របនឹងសន្ធិសញ្ញានេះ។

## មាត្រា១៩
## អ្នកតម្កល់លិខិតុបករណ៍

អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបានតែងតាំងជាអ្នកតម្កល់លិខិតុបករណ៍នៃសន្ធិសញ្ញានេះ។

## មាត្រា២០
## អត្ថបទច្បាប់ដើម

ច្បាប់ដើមនៃសន្ធិសញ្ញានេះ មានជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញដែលមានតម្លៃស្មើៗគ្នា។

ធ្វើនៅញូវយ៉ក ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៧។ ៚



Media from www.moj.gov.kh resource from www.ocm.gov.kh

# TREATY ON THE PROHIBITION OF NUCLEAR WEAPONS

UNITED NATIONS

2017

# TREATY ON THE PROHIBITION OF NUCLEAR WEAPONS

*The States Parties to this Treaty,*

*Determined* to contribute to the realization of the purposes and principles of the Charter of the United Nations,

*Deeply concerned* about the catastrophic humanitarian consequences that would result from any use of nuclear weapons, and recognizing the consequent need to completely eliminate such weapons, which remains the only way to guarantee that nuclear weapons are never used again under any circumstances,

